# «យើងមានជីវភាពក្រីក្រ និងគោកយ៉ាក» : អង្គជំនុំជម្រះចាប់ផ្តើមសវនាការលើករណី០០២

ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២

**ដោយ វ៉េនឌល ឌីហ្សាលក្វ**

ប្រែសម្រួលដោយ ជា ផល្លា

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ផ្តើមដំណើរការលើអង្គសេចក្តីក្នុងសំណុំរឿង០០២របស់ខ្លួនប្រឆាំងទៅនឹងជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន បន្ទាប់ពីវិសមកាលបុណ្យគ្រីស្តម៉ាសរួចមក ។ នៅពេលដែលអង្គសវនាការចាប់ផ្តើមនៅពេលព្រឹក កន្លែងអង្គុយនៅមានទំនេមួយចំនួន ដោយអ្នកចូលរួមបានអង្គុយកៅអីត្រឹមតែបីភាគប៉ុណ្ណោះ ។ នៅពេលព្រឹក សវនាការចាប់ផ្តើមនូវការធ្វើសក្ខីកម្មរបស់ នួន ជា ដែលធ្លាប់បានធ្វើយ៉ាងវែងរួចមកហើយ កាលពីចាប់ផ្តើមសវនាការថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ មកម្ល៉េះ ។

ថ្ងៃទីមួយនៃដំណើរការសវនាការក្នុងឆ្នាំ២០១២នេះ ស្រដៀងគ្នាទៅនឹងសវនាការលើកមុនៗ ភាគីការពារក្តីនៅតែលើកឡើងពីបញ្ហាជ្រៀតជ្រែកខាងនយោបាយដដែលៗ ចំណែកឯការចងចាំរបស់សាក្សីទៀតសោធនៅតែមានកម្រិតនៅឡើយ ។ ចំពោះ នួន ជា នៅតែជំទាស់អំពីឯកសារថតចម្លងដោយទទូចទាមទារតុលាការបង្ហាញនូវឯកសារជាច្បាប់ដើមដល់ខ្លួនមើល ។

គួរបញ្ជាក់ផងដែរថា សំនួរដែលបានចោទសួរនៅពេលព្រឹកក្នុងអង្គសវនាការ គឺនិយាយអំពីប្រវត្តិរបស់ចលនាខ្មែរក្រហម ។

## មេធាវីការពារក្តីរបស់ នួន ជា ស្នើឲ្យអង្គជំនុំជម្រះប្រានចោលសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន

មុននឹង នួន ជា ឡើងធ្វើសក្ខីកម្ម ក្រុមមេធាវីការពារក្តីរបស់ នួន ជា បានស្នើជាផ្លូវការមួយទៅកាន់អង្គជំនុំជម្រះ ដើម្បីឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍ថ្មីៗ ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាក់ទងទៅនឹង នួន ជា ។ យោងតាមអត្ថបទសារព័ត៌មានវៀតណាមមួយបានឲ្យដឹងថា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងទៅកាន់គណៈប្រតិភូវៀតណាមកាលពីពេលថ្មីៗនេះថា "ការអះអាងរបស់ នួន ជា គឺជាការមិនពិតទេ» ហើយថា នួន ជា គឺជា«ឃាតករ» និងជា«ជនដៃដល់នៃអំពើប្រល័យពូជសាសន៍» ។ សហមេធាវីបានអះអាងថា ប្រសាសន៍របស់នាយករដ្ឋមន្ត្រី គឺជាការរំលោភដល់សិទ្ធិរបស់ នួន ជា ក្នុងនាមតុលាការយុត្តិធម៌មួយ ជាពិសេសសិទ្ធរបស់ នួន ជា ក្នុងនាមជាជន

ស្មោះត្រង់ ។ សហមេធាវីបានដកស្រង់ពីយុទ្ធសាស្ត្រទាក់ទងនឹងបញ្ហានេះពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ។ សហមេធាវីការពារក្តីរបស់ នួន ជា បានបញ្ជាក់ថា សេចក្តីថ្លែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន អាចធ្វើឲ្យសាធារណជនមានការវាយតម្លៃខុសទៅលើ នួន ជា ហើយក៏បានដាក់សម្ពាធឲ្យចៅក្រមរបស់អង្គជំនុំជម្រះអាចដាក់ពិរុទ្ធមកលើ នួន ជា បាន ។ សហមេធាវីការពារក្តីបានបញ្ជាក់ផងដែរថា ពាក្យសម្តីនេះ ជះឥទ្ធិពលខ្លាំងណាស់នៅប្រទេសកម្ពុជា ដោយសារតែការកង្វះនូវភាពឯករាជ្យក្នុងប្រព័ន្ធតុលាការ ។ សរុបមក សហមេធាវីការពារក្តីរបស់ នួន ជា យល់ឃើញថា អង្គជំនុំជម្រះមានកាតព្វកិច្ច “ប្រានចោលជាផ្លូវការ” នូវសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី ដើម្បី“ការពារអធិបតេយ្យភាពរបស់តុលាការ” ។ ជាមួយគ្នានោះ អង្គជំនុំជម្រះមិនបានប្រតិកម្មតបទៅនឹងសំណើរបស់សហមេធាវីការពារក្តីរបស់ នួន ជា ទេ តែអង្គសវនាការបានអះអាងអំពីការបដិសេធកាលពីលើកមុនរបស់ នួន ជា ដែលមិនទទួលស្គាល់ឯកសារថតចម្លងនៅក្នុងសំណុំរឿង ក្នុងអំឡុងពេលនៃដំណើរការសវនាការ ។ អង្គសវនាការបានបង្គាប់ថា ក្រោមវិធានផ្ទៃក្នុង៨៧(១) របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះមានសិទ្ធ និងសម្រេចថាតើឯកសារណាមួយដែលត្រូវយកមកប្រើ ហើយអង្គសវនាការមានសិទ្ធក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ក៏ដូចជាអនុញ្ញាតឲ្យមានការប្រើប្រាស់ឯកសារថតចម្លង ព្រោះឯកសារនោះមានការពាក់ព័ន្ធគ្នា ព្រមទាំងបានបានផ្ទៀងផ្ទាត់រួចហើយ ។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា តម្លៃនៃអង្គហេតុរបស់ឯកសារទាំងនោះ នឹងត្រូវអះអាងដោយចៅក្រមជាច្រើនរូបនៅថ្ងៃក្រោយទៀត ហើយនាពេលបច្ចុប្បន្ននេះអង្គសវនាការនិយាយតែអំពីការដាក់បញ្ចូលឯកសារទៅក្នុងសំណុំរឿងប៉ុណ្ណោះ ។

## សក្ខីកម្មរបស់ នួន ជា

ក្រោយពីបញ្ហាមួយចំនួនបានបញ្ចប់ នួន ជា បានស្នើទៅអង្គជំនុំជម្រះ គាត់សុំធ្វើសក្ខីកម្មតែពេលព្រឹកប៉ុណ្ណោះដោយសារបញ្ហាសុខភាព ។ នួន ជា បានអះអាងថា “ក្បាល និងបេះដូង”របស់គាត់មិនអាចអនុញ្ញាតឲ្យគាត់ធ្វើសក្ខីកម្មលើសពីពេលព្រឹកបានទេ ។ ជាមួយគ្នានោះដែរអង្គជំនុំជម្រះសម្រេចទទួលយកសំណើទាំងនេះ រួចបន្តនីតិវិធីដោយប្រគល់តួនាទីទៅព្រះរាជអាជ្ញាដើម្បីបន្តសួរសំនួរទៅកាន់ នួន ជា ដោយផ្តោតទៅលើទស្សនាវដ្តីទង់បដិវត្តន៍ ទស្សនាវដ្តីទង់ក្រហម និងទស្សនាវដ្តីយុវជន-យុវនារីបដិវត្តន៍របស់ខ្មែរក្រហម ។ អំឡុងពេលនៃការធ្វើសក្ខីកម្ម នួន ជា ហាក់បីដូចជាជំទាស់ និងធុញថប់ទៅនឹងសំនួរដែលបានចោទសួរមកលើគាត់ ។ នួន ជា បានអះអាងថា គាត់មិនចាំរឿងរ៉ាវហេតុការណ៍សំខាន់ៗមួយចំនួន ក៏ដូចជាឈ្មោះកម្មាភិបាលខ្មែរក្រហមដែលមាននៅក្នុងរូបថតដែរ ។ នួន

ជា នៅតែស្នើទៅកាន់តុលាការ ក៏ដូចជាព្រះរាជអាជ្ញាឲ្យយកឯកសារដើមមកបង្ហាញខ្លួនមើល និងបានបដិសេធចោលរាល់ឯកសារថតចម្លងទាំងឡាយដែលយកមកប្រើក្នុងអង្គសវនាការនេះ ។

ព្រះរាជអាជ្ញាបានសួរទៅ នួន ជា អំពីប្រធានបទទាក់ទងទៅនឹងកំណារកំណើតរបស់ទស្សនាវដ្ដីទង់បដិវត្តន៍ ។ នួន ជា បានបញ្ជាក់ថា ទស្សនាវដ្ដីទង់បដិវត្តន៍ដំបូងឡើយ គឺជាសៀវភៅដែលសរសេរដោយដៃប៉ុណ្ណោះ បានធ្វើឡើងក្រោយពីសន្និសិតទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៤ ស្របពេលដែលប្រទេសកម្ពុជា ឡាវ និងវៀតណាមទទួលបានឯករាជ្យពីបារាំង ។ នួន ជា បានបញ្ជាក់ទៀតថា ទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានចែកចាយដើម្បី“សាងទំនុកចិត្តក្នុងចំណោមអ្នកស្នេហាជាតិ និងជនបដិវត្តន៍” ក្នុងគោលបំណងបង្រួបបង្រួមក្រុមផ្សេងៗទៀតក្នុងអំឡុងពេលនៃ“ភាពវឹកវរ” ក្រោយពីកិច្ចព្រមព្រៀងរួចមក ។ នួន ជា បន្តថា សៀវភៅតូចដែលសរសេរដោយដៃត្រូវបានវាយជាអក្សរពុម្ព ហើយបោះពុម្ពប្រហែលជាចំនួន២០ក្បាល ដើម្បីផ្សព្វផ្សាយពីមាគ៌ាបក្សរបស់ខ្មែរក្រហម ។ នួន ជា បាននិយាយទៀតថា ក្រោយពីខ្មែរក្រហមទទួលបានអំណាចក្នុងឆ្នាំ១៩៧៥ ទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានជំនួសដោយកូនសៀវភៅទង់ក្រហមវិញ ដែលបានបោះពុម្ពជាអក្សរពុម្ពនៅទីក្រុងភ្នំពេញ ។

ក្រោយពីនិយាយបន្តិចបន្តួចទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្តន៍ និងទស្សនាវដ្ដីទង់ក្រហម នួន ជា ហាក់បីដូចជាមានចេតនាលែងសហការ ហើយពេលខ្លះគាត់បានប្រកែកតវ៉ាជាមួយព្រះរាជអាជ្ញាក្នុងពេលសួរសំនួរ ។ មួយវិញទៀត នួន ជា បានអះអាងថា គាត់មិនដឹងអំពីយុវជនបដិវត្តន៍ ដែលបង្កើតឡើងដោយខ្មែរក្រហមទេ ហើយគាត់បានជំទាស់ដោយមិនទទួលស្គាល់និងអានឯកសារថតចម្លងនោះទេ លុះត្រាតែតុលាការយកឯកសារដើមមកបង្ហាញ ។ លើសពីនេះទៀត នួន ជា បានបញ្ជាក់ថា ឯកសារថតចម្លងគឺមានទម្រង់ផ្សេងពីឯកសារដើម ដោយទាញយកហេតុផលថា ឯកសារចម្លងមិនមានគម្របពណ៌ក្រហមដូចសៀវភៅដើម ហើយអក្សរក៏តូចជាងដែរ ។

## អៀង សារី សុំចេញពីបន្ទប់សវនាការ

មុននឹងដល់ម៉ោងសម្រាកនៅពេលព្រឹក មេធាវីការពារក្ដីរបស់ អៀង សារី បាននិយាយកាត់ព្រះរាជអាជ្ញាកំពុងសួរសំនួរទៅកាន់ នួន ជា ដោយស្នើទៅអង្គសវនាការថា អៀង សារី មិនសូវស្រួលខ្លួន ហេតុដូចនេះសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យ អៀង សារី ទទួលការព្យាបាលពីគ្រូពេទ្យ ។ អង្គជំនុំជម្រះបានយល់ព្រម ហើយ អៀង សារី បានចាកចេញពីបន្ទប់សវនាការ ។ ក្រោយពីទទួលបានការពិនិត្យសុខភាពរួចមក អៀង សារី បានសុំស្នើសិទ្ធមិនបង្ហាញខ្លួនក្នុងសវនាការ ដោយចូលរួមតាមរយៈប្រព័ន្ធសោទស្សន៍នៅបន្ទប់រង់ចាំខាងក្រោមវិញ ។ ចំពោះការដែល អៀង សារី សុំសិទ្ធិក្នុងការ

មិនចូលរួមក្នុងដំណើរការសវនាការ និងចេញពីបន្ទប់សវនាការនេះ បានធ្វើឲ្យមានការព្រួយបារម្ភមួយ ដែលបង្ហាញឲ្យឃើញថាសុខភាពរបស់គាត់កាន់តែមានសភាពដុនដាបទៅៗ ។

## ការសួរសំនួរទៅកាន់ នួន ជា បន្តទៀត

បន្ទាប់ពីសម្រាក ២០នាទី នៅពេលព្រឹករួច សវនាការបានបន្តដោយព្រះរាជអាជ្ញាចាប់ផ្តើមចោទជាសំនួរទាក់ទងទៅនឹងសមាជបក្សក្នុងឆ្នាំ១៩៦០ ដែលពេលនោះបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតជាផ្លូវការ ។ នួន ជា មើលទៅដូចជាមានការធុញទ្រាន់ពេលដែលនិយាយអំពីសមាជបក្សនោះ ព្រោះគាត់បានធ្លាប់និយាយរួចមកហើយ ។ នួន ជា បាននិយាយថា សមាជបក្សឆ្នាំ១៩៦០ កើតឡើងដោយការសម្រេចរបស់ ទូ សាមុត, ម៉ី ម៉ាន់, ប៉ុល ពត និងខ្លួនគាត់ផ្ទាល់ដើម្បី“ផ្តាច់ខ្លួន”ចេញពីបក្សកុម្មុយនីស្តឥណ្ឌូចិនដែលគ្រប់គ្រងដោយវៀតណាម ហើយក្នុងនោះ ប្រទេសឡាវក៏ស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាមដែរ ។ នួន ជា បានបញ្ជាក់ទៀតថា ក្នុងអំឡុងសមាជចំនួនបីថ្ងៃ ទូ សាមុត ត្រូវបានតែងតាំងជាលេខាបក្ស នួន ជា ជាអនុលេខាបក្សទទួលបន្ទុកជនបទ និង ប៉ុល ពត គឺជាគណៈអចិន្ត្រៃយ៍ទទួលបន្ទុកខាងកិច្ចការនៅទីក្រុង ។ នួន ជា បានបន្ថែមទៀតថា ម៉ី ម៉ាន់ បានចាកចេញពីបក្ស ពីព្រោះគាត់រៀបការ និងដោយសារគាត់មិនអាចបំពេញតួនាទីរបស់គាត់បានខ្ជាប់ខ្ជួន ។

ព្រះរាជអាជ្ញាបានបន្តសួរសំនួរទៅ នួន ជា ទៀតអំពីអ្នកចូលរួមផ្សេងទៀតក្នុងសមាជឆ្នាំ១៩៦០ និងអំពីតួនាទីរបស់អ្នកចូលរួមទាំងនោះ ។ បន្ទាប់ពីព្រះរាជអាជ្ញាសួរនូវសំនួរទាំងនោះ នួន ជា ហាក់ដូចជាបាត់ភាពអត់ធ្មត់និងភ្លេចខ្លះៗនូវសំនួរដែលបានសួរមកគាត់ ។ នួន ជា បានបញ្ជាក់ថា អៀង សារី ត្រូវបានតែងតាំងជាសមាជិកគណៈអចិន្ត្រៃយ៍ជាមួយ សុន សេន ហើយ សូ ភឹម, វ៉ន វ៉េត និង តាម៉ុក គឺជាគណៈមជ្ឈឹមនៅពេលនោះ ។ នួន ជា បានបន្តថា កែវ មាស កាលពីដំបូងក៏ជាគណៈមជ្ឈឹមដែរ តែក្រោយមកត្រូវបានដកចេញពីគណៈកម្មការនេះវិញ នៅក្នុងឆ្នាំ១៩៦១ ព្រោះគាត់“បើកទូលាយពេក” ។

ក្រោយមកព្រះរាជអាជ្ញាបានបង្ហាញរូបថតមួយសន្លឹកដែលថតពេលសមាជ នៅឆ្នាំ១៩៦០ នៅលើអេក្រង់កុំព្យូទ័រ ព្រមទាំងបានស្នើឲ្យ នួន ជា រៀបរាប់ពីអត្តសញ្ញាណអ្នកដែលនៅក្នុងរូបថតនោះ ។ តែ នួន ជា ហាក់បីដូចជាមិនសូវសហការទេ បានត្រឹមតែឆ្លើយថា គាត់មិនចាំអ្នកដែលមាននៅក្នុងរូបថតនោះទេ អ្វីដែលគួរឲ្យកត់សម្គាល់ខ្លាំងបំផុតនោះសូម្បីតែរូបរបស់ ប៉ុល ពត និងរូបខ្លួនគាត់ផ្ទាល់ក៏មិនចំណាំផង ។ នួន ជា បានអះអាងថា បុរសម្នាក់នៅក្នុងរូបថតដែលព្រះរាជអាជ្ញាបញ្ជាក់ថាជារូបខ្លួននោះគឺ ជាសាស្រ្តាចារ្យម្នាក់ដែលមានមុខមាត់ស្រដៀងនឹងខ្លួននោះទេ ។ វាពិតជារឿងចម្លែកណាស់ដែល នួន ជា មិនស្គាល់រូបបដិវត្តន៍របស់ខ្លួន និងអ្នកដែលគាត់ធ្លាប់ធ្វើការជាមួយអស់ជាច្រើន

ទសវត្សរ៍មកនោះ ។ ប៉ុន្តែ នួន ជា បែរជាស្គាល់ និងរៀបរាប់រូបរបស់ ម៉ាក្ស, អង់គេល, ឡេនីន និងស្តាលីន ដែលព្យួរនៅលើជញ្ជាំងយ៉ាងក្បោះក្បាយទៅវិញ ។

ដោយសារតែ នួន ជា មិនចំណាំអ្នកដែលមាននៅក្នុងរូបថតទាំងអស់នោះ ព្រះរាជអាជ្ញាបាន ងាកទៅរកប្រធានបទផ្សេងទៀតដែលទាក់ទងទៅនឹងសមាជបក្សក្នុងឆ្នាំ១៩៦០ ដោយយោងទៅលើអ្វី ដែលបានរៀបរាប់នៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ។ ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ពីអត្ថបទមួយ នៅក្នុងទស្សនាវដ្តីនោះដែលមានចំណងជើងថា «ការវិភាគទៅលើធាតុពិតនៃសង្គមកម្ពុជានិងអំពីរបៀប កម្ចាត់ពួកសក្តិភូមិ» ។ ព្រះរាជអាជ្ញាបានស្នើរឲ្យ នួន ជា បង្ហាញអំពីភាពខុសប្លែកគ្នារវាងអ្វី ដែលជា ទំនាស់«ផ្ទៃក្នុង» ទំនាស់«បដិបក្ខ» និងទំនាស់«ស្លាប់រស់» ។

សំនួរជាហូរហែមកទៀតត្រូវបានជំទាស់ដោយ នួន ជា ហើយនៅតែទាមទារចង់បានឯកសារ ដើម មិនមែនជាឯកសារថតចម្លង ។ ការដែល នួន ជា បដិសេធបែបនេះធ្វើឲ្យអ្នកតាមដានដំណើរការ តុលាការមានការធុញថប់ទៅនឹងការបដិសេធនេះ ។ ទន្ទឹមនឹងការបដិសេធ នួន ជា បានឆ្លើយតបទៅ នឹងអ្វីដែលព្រះរាជអាជ្ញាបានសួរដែលទាក់ទងទៅនឹង«ទំនាស់» :

> ពាក្យថាទំនាស់«ផ្ទៃក្នុង» ទំនាស់«បដិបក្ខ» និងទំនាស់«ស្លាប់រស់»នោះ គឺគ្រាន់តែជាការបកស្រាយរបស់លោកប៉ុណ្ណោះ ហើយខ្ញុំសុំឲ្យលោក យកឯកសារដើមមកឲ្យខ្ញុំមើល ទើបខ្ញុំអាចធានាថា ឯកសារនោះវា មានភាពពិតប្រាកដបាន... បើមិនដូច្នេះទេ ខ្ញុំមិនអាចឆ្លើយតបទៅនឹង ពាក្យដែលលោកអះអាងបានទេ ។ បើតាមខ្ញុំយល់ពាក្យនោះគឺជាពាក្យ លោកប្រើដោយខ្លួនឯង.... ខ្ញុំខ្លាចថា ពាក្យនោះប្រើដើម្បីគោលដៅអ្វី មួយ ។

ក្រោយពីព្រះរាជអាជ្ញាសួរសំនួរដដែលៗច្រើនលើកច្រើនសារនោះ នួន ជា បានពន្យល់ថា ទំនាស់«បដិបក្ខ» គឺជាជម្លោះរវាងប្រទេសដែលឈ្លានពានពីខាងក្រៅមកលើប្រទេសកម្ពុជា និងរវាង ម្ចាស់ដីបរិវារបរទេស និងកសិករដែលទទួលរងនូវការកេងប្រវ័ញ្ច ។ ជម្លោះនេះមិនអាចដោះស្រាយ បានទេ ហើយបង្កទៅជាជម្លោះ«ស្លាប់រស់» ។ ផ្ទុយមកវិញ ទំនាស់«ផ្ទៃក្នុង» គឺជាការជជែកតវ៉ាគ្នាតិច តួចអំពីគោលនយោបាយល្អណាមួយដែលត្រូវយកមកអនុវត្តិ ហើយជម្លោះត្រូវដោះស្រាយក្នុងអំឡុង ពេលប្រជុំនិងការចរចារគ្នា ។

អំឡុងពេលនៃការពិភាក្សាគ្នានោះ នួន ជា បានប្រៀបធៀបស្ថានភាពកសិករកម្ពុជាក្នុង ទសវត្សរ៍៦០ និងក្នុងទសវត្សរ៍៧០ ជាមួយនឹងជម្លោះដីធ្លីនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាដោយ

បញ្ជាក់ថា ទាក់ទងទៅនឹងទំនាស់«បដិបក្ខ» មេដឹកនាំខ្មែរក្រហមត្រូវពិនិត្យមើលបញ្ហានោះដើម្បីមើលអំពីទំហំនៃជម្លោះនោះ ហើយ នួន ជា បានស្នើទៅអង្គជំនុំជម្រះឲ្យ«ក្រឡេកមើលអំពីជម្លោះដីធ្លី ដែលកំពុងតែកើតឡើងសព្វថ្ងៃនេះ ។ លោកឃើញហើយថា មនុស្សមួយចំនួនបានសម្លាប់ខ្លួនដោយលោតទឹក ហើយលោកអាចឆ្លុះបញ្ចាំងមើលពីស្ថានភាពនោះដែរ» ។

នៅពេលសួរសំនួរបន្តទៀត នួន ជា ឈប់ដោយបញ្ជាក់ត្រង់ៗថា បក្សកុម្មុយនីស្តកម្ពុជាគឺដើម្បីក្តាប់ភាពការណ៍អំពីទំនាស់«បដិបក្ខ»នៅក្នុងប្រទេសកម្ពុជា ស្របពេលនោះព្រះរាជអាជ្ញាបានជម្រុញសួរ នួន ជា បន្តទៀតដើម្បីឲ្យគាត់ឆ្លើយថា តើមានរឿងអ្វីកើតឡើងបើសិនជានរណាម្នាក់បង្កមានទំនាស់នោះ ។

ជាការបង្វែរនឹងការមិនឆ្លើយ នួន ជា ទាមទារសុំមើលឯកសារដើម ដោយបញ្ជាក់ច្បាស់ៗថា «ខ្ញុំទទូចម្តងហើយម្តងទៀតថា ខ្ញុំមិនអាចឆ្លើយសំនួរនេះបានទេ ។ មនុស្សជប់មានគំនិតជប់ ត្រូវតែប្រើឯកសារដើមមួយជាមូលដ្ឋានដើម្បីពិភាក្សា» ។ ដោយ នួន ជា មិនសហការល្អក្នុងការឆ្លើយសំនួរ ព្រះរាជអាជ្ញា បានសួរសំនួរថ្មីមួយផ្សេងទៀតអំពីគោលនយោបាយក្នុងការបង្កើតបណ្តាញនៅជនបទក្នុងប្រទេសកម្ពុជា ។ ជាថ្មីម្តងទៀត នួន ជា នៅតែបង្ហាញពីអារម្មណ៍ធុញថប់ ហើយបញ្ជាក់ទៅកាន់ព្រះរាជអាជ្ញាថា «សំនួរនេះប្រាំដែល ដូច្នេះខ្ញុំមិននិយាយរឿងនេះទៀតទេអំពីមាគ៌ាយុទ្ធសាស្ត្រ វាខាតពេលខ្ញុំដែលឆ្លើយនឹងសំនួររបស់លោកទៀត» ។

ឆ្លើយនឹងសំនួរបន្ទាប់របស់ព្រះរាជអាជ្ញា នួន ជា បានបញ្ជាក់ថា ខ្មែរក្រហមចាប់ផ្តើមធ្វើបដិវត្តន៍ពីជនបទមុន ព្រោះអ្នកនៅទីក្រុង«មានជីវភាពរស់នៅគ្រប់គ្រាន់ តែអ្នកនៅជនបទមានជីវភាពក្រណាស់» ហើយនេះគឺជាផ្នែកផ្ការបស់បក្ស ។ អ្នករស់នៅជនបទមិនមានទាំង«របស់ស្លៀកពាក់ផង»ដូច្នេះ បក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើម«អប់រំអ្នកទាំងនោះ»មុន ។

នួន ជា បានបន្តថា ចលនាខ្មែរក្រហម «មិនមានសត្រូវនៅជនបទទេ សត្រូវក៏មិន អាចទៅទីនោះបានដែរ ។ មានតែកសិករប៉ុណ្ណោះ ដូច្នេះការងារអាចធ្វើទៅដោយរលូន ហើយមួយទៀតអ្នកនៅជនបទគឺជាអ្នកក្រនិងអាចផ្តល់ឱកាសឲ្យអ្នកទាំងនោះអាចមានអាហារហូបចុកនិងរបស់របរស្លៀកពាក់» ។

សំនួរចំចំណុចរបស់ព្រះរាជអាជ្ញាអំពីមាគ៌ាបក្សបានធ្វើឲ្យ នួន ជា បដិសេធម្តងទៀត ហើយគាត់មិនឆ្លើយអំពីសំនួរនេះទេដោយសំអាងថា មិនមានឯកសារដើម ។ អ្នកតាមដានតុលាការមានការគួញត្អែរដែរនៅពេលនោះ ។ មេធាវីការពារក្តីរបស់ នួន ជា បានងើបឡើងដើម្បីអះអាងថា នួន ជា បានបញ្ជាក់ ដោយសមញ្ញហើយថា គាត់បដិសេធរាល់ឯកសារដែលបានថតចម្លង ហើយថា នួន ជា មើលឃើញថា ឯកសារដែលថតចម្លងនោះហាក់បីដូចជាមិនស៊ីគ្នា ដូចជាទំហំអក្សរ ពណ៌ និងទម្រង់នៃ

ការសរសេរជាដើម ។ មេធាវីការពារក្ដីរបស់ អៀង សារី បានបន្ថែមទៀតថា នៅតុលាការអន្តរជាតិនានា ឯកសារទាំងអស់ត្រូវបានបញ្ជាក់ឲ្យច្បាស់ពីភាពពិតត្រឹមត្រូវនូវរាល់ឯកសារថតចម្លងដែលត្រូវដាក់នៅចំពោះមុខតុលាការ និងបានស្នើថាអង្គជំនុំជម្រះថាគួរប្រើយន្តការនោះដែរ ។

ទន្ទឹមនឹងនោះ ព្រះរាជអាជ្ញាបានកត់សម្គាល់ថា សវនាការអំពីបញ្ហាភស្តុតាងត្រូវបានកំណត់ពេលវេលារួចហើយនៅសប្ដាហ៍ក្រោយ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយថា ឯកសារថតចម្លងត្រូវបានបញ្ចូលនៅក្នុងសំណុំរឿងរាប់ខែរាប់ឆ្នាំមកហើយ ព្រមទាំងបញ្ជាក់ថា បើសិនជាក្រុមការពារក្ដីជំទាស់ទៅនឹងភាពពិតរបស់ឯកសារទាំងនោះ គួរតែលើកមកនិយាយនៅពេលនោះមិនមែនពេលនេះទេ ។

អង្គជំនុំជម្រះយល់ពីជំហររបស់គ្រប់ភាគីទាំងអស់ ហើយក្រោយមកក៏ប្រកាសសម្រាកអាហារថ្ងៃត្រង់ ។

## សក្ខីកម្មរបស់ រម៉ម យុន

ក្រោយពីសម្រាកអាហារថ្ងៃត្រង់រួចមក អង្គជំនុំជម្រះបានប្ដូរកម្មវិធីដោយអនុញ្ញាតឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណី រម៉ម យុន និង ក្លាន ហ៊ុត ធ្វើសក្ខីកម្មវិញដោយបន្តពីខែមុន ។ ភាគីការពារក្ដីនីមួយៗត្រូវបានផ្ដល់ពេលឲ្យសួរសំនួរទៅកាន់ រម៉ម យុន ដែលធ្លាប់បានសួរដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយ ។ ក្រុមមេធាវីការពារក្ដី នួន ជា មិនមានសំណួរទៅកាន់ រម៉ម យុន តែបានបញ្ជាក់ថា ការធ្វើសក្ខីកម្មទៅលើ រម៉ម យុន គួរតែកំណត់ត្រឹមតែប្រធានបទទាក់ទងនិងជំងឺផ្លូវចិត្តបានហើយ ព្រោះគាត់គឺជាដើមបណ្ដឹងរដ្ឋប្បវេណី មិនមែនជាសាក្សីទេ ។ ដូច្នេះ មេធាវីការពារក្ដីរបស់ នួន ជា បានអះអាងថា ការធ្វើសក្ខីកម្មរបស់ រម៉ម យុន មិនទាក់ទងទៅនិងដំណើរការសវនាការទេ ។

ការដែលឆ្លើយបែបនេះធ្វើឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបវិញដែរ ដោយបានគូសបញ្ជាក់ថា ក្នុងនាមជាភាគីមួយដែលមានសិទ្ធិពេញលេញក្នុងសវនាការនេះ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកធ្វើការបង្ហាញ មានសិទ្ធិនិយាយពីការពិតដែលពាក់ព័ន្ធនឹងករណីណាមួយនៅចំពោះមុខ អង្គជំនុំជម្រះ ។

ជាមួយគ្នានោះមេធាវីការពារក្ដីរបស់ ខៀវ សំផន បានក្រោកឈរដើម្បីគាំទ្រនូវអ្វីដែលក្រុមការពារក្ដី នួន ជា លើកឡើង និងបានបន្ថែមទៀតថា អង្គជំនុំជម្រះបាន«ខ្ជះខ្ជាយ»ពេលយ៉ាងច្រើនដែលអនុញ្ញាតឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីឡើងមកធ្វើសក្ខីកម្មលើសពីដែនកំណត់របស់ខ្លួន ។ មេធាវីរបស់ ខៀវ សំផន បានស្នើថា អង្គជំនុំជម្រះគួរតែ«ច្រានចោលសក្ខីកម្មទាំងអស់ ដែលធ្វើដោយភាគីរដ្ឋប្បវេណី ព្រោះនេះមិនមែនជាតួនាទីរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការបង្ហាញពីការពិតទេ»

ភ្លាមៗនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបដិសេធ«យ៉ាងដាច់អហង្ការ»ទៅនឹងអ្វីដែលបាន អះអាងដោយមេធាវីការពារក្តីរបស់ ខៀវ សំផន។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិធ្វើសក្ខីកម្មទាក់ទងនឹងអង្គហេតុពិត ចំពោះករណី០០១ និង០០២ ដរាបណាភាគីដើមបណ្តឹងរដ្ឋប្បវេណីដឹងរឿងរ៉ាវនោះ។ ព្រះរាជអាជ្ញាបញ្ជាក់ដោយសមញ្ញថា នេះមិន មែនជារឿងរបស់ភាគីការពារក្តីក្នុងការសម្រេចថាសក្ខីកម្មណាមួយជារឿងខាតពេលនោះទេ ហើយ ភាគីការពារក្តីក៏មិនមានសិទ្ធិវាយតម្លៃលើសក្ខីកម្មណាមួយដែរ។ អំណាចនេះគឺជាភារកិច្ចរបស់ចៅក្រម របស់អង្គជំនុំជម្រះ។

ប្រធានចៅក្រម និល ណុន បានរំលឹកទៅភាគីការពារក្តីទាំងអស់ថា នេះគឺជាឱកាសដែលភាគី ការពារក្តីត្រូវឡើងសួរសំនួរទៅកាន់ រម៉ម យុន ហើយចៅក្រមបានសួរថាតើចង់សួរជាសំនួរឬអត់?

មានតែក្រុមការពារក្តីរបស់ អៀង សារី ប៉ុណ្ណោះទាញឱកាសដើម្បីសួរទៅកាន់ រម៉ម យុន ទាក់ទងទៅនឹងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបាននិយាយរួចហើយកាលពីលើកមុន។ តាមរយៈ ការសាកសួរនេះ ធ្វើឲ្យមានភាពច្បាស់លាស់ដោយ រម៉ម យុន បានសារភាពថា ការចងចាំរបស់ គាត់មានការធ្លាក់ចុះ ហើយគាត់សុំពេលគិតមួយសន្ទុះមុននឹងឆ្លើយទាក់ទងទៅនឹងកាលបរិច្ឆេទ និង ព្រឹត្តិការណ៍ណាមួយ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានជំទាស់ជាច្រើនលើកច្រើនសារ ចំពោះសំនួររបស់ភាគីការ ពារក្តី ដោយអះអាងថា ភាគីការពារក្តីសួរសំនួរដោយគ្មានទាក់ទងនឹងប្រធានបទ និង«ទទួលយកផល ប្រយោជន៍»ពីការចងចាំរបស់ រម៉ម យុន ដែលកំពុងតែចុះខ្សោយ។ ក្រុមអ្នកច្បាប់របស់ដើមបណ្តឹង រដ្ឋប្បវេណីបានបញ្ជាក់ថា ក្រុមការពារក្តី អៀង សារី គួរតែរៀបចំសួរសំនួរទាក់ទងទៅនឹងប្រធានបទ ជាក់លាក់ណាមួយក្នុងវគ្គសវនាការបឋមក្នុងសំណុំរឿង០០២។

អង្គជំនុំជម្រះបានធ្វើការជំទាស់ទៅនឹងក្រុមអ្នកច្បាប់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំ ជម្រះបានបញ្ជាក់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជ្រើសរើសដោយមេធាវីដើមបណ្តឹងរដ្ឋប្ប វេណី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវឆ្លើយសំនួរទាំងអស់នូវអ្វីដែលមានការចោទសួរ។

ក្រោយពីដឹងថា ការចងចាំរបស់ រម៉ម យុន មានការចុះខ្សោយច្រើនតាមរយៈការសួរនាំជា ច្រើនសំនួរដោយក្រុមការពារក្តីរបស់ អៀង សារី រួចមក ចៅក្រម ឡាវ៉ែញ បានសួរទៅកាន់ រម៉ម យុន ថាតើថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មានអត្ថន័យយ៉ាងណាចំពោះលោក? រម៉ម យុន បាន ឆ្លើយថា គាត់មិនដឹងថាថ្ងៃនោះមានរឿងអ្វីកើតឡើងទេ ព្រោះវាបានកន្លងទៅយូរហើយ ដោយគ្មាន នរណារំលឹកគាត់ទេ«រឿងនេះនឹកមិនឃើញសោះ»។ រម៉ម យុន មិនអាចនឹកឃើញពីកាលបរិច្ឆេទថ្មីៗ

ទេ ហើយគាត់បានសួរទៅអ្នកតំណាងរបស់អង្គភាពគាំពារសាក្សីរបស់តុលាការដែលកំពុងអង្គុយនៅជិតនោះថាតើសំណួរចង់សួរពីអី ។ រ៉ម យុន បានបញ្ជាក់ថា គាត់ដឹងពីការវាយបែកទីក្រុងភ្នំពេញដោយខ្មែរក្រហម តែគាត់មិនចាំថ្ងៃខែនិងព្រឹត្តិការណ៍នោះទេ ។ គាត់បាននិយាយទៀតថា អ្វីដែលគាត់ចាំគឺគ្រាន់តែជារឿងរ៉ាវដែលកើតឡើងនៅមូលដ្ឋានរបស់គាត់ប៉ុណ្ណោះ ។ កាលនោះគាត់រស់នៅមូលដ្ឋានរបស់គាត់ពេលដែលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ ។ រ៉ម យុន បានបញ្ជាក់ទៀតថា ដោយសារតែគាត់ជាកូនអ្នកតូចតាច គាត់មិនដែលបានធ្វើធំអ្វីទេ ។

ដោយសារពីដំបូង រ៉ម យុន មិនអាចនឹកឃើញរឿងហេតុការណ៍ទាក់ទងនឹងករណី០០២ គាត់ចាប់ផ្តើមផ្តល់សក្ខីកម្មដោយរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ក្នុងរបបខ្មែរក្រហម រួមទាំងការរៀបរាប់ពីវិស័យកសិកម្ម និងគោលនយោបាយរបស់ខ្មែរក្រហមផង ។ រ៉ម យុន បានអះអាងថា ក្នុងនាមជាលេខាស្រុកម្នាក់ គាត់បានធ្វើការយ៉ាងអស់ពីសមត្ថភាពដើម្បីដឹកនាំប្រជាជនក្រោមឱវាទរបស់គាត់ដើម្បីធ្វើខ្លួនទៅជាកសិករល្អ តែគាត់មានកំហុសជាច្រើនដោយសារតែគាត់មិនបានធ្វើតាមផែនការ ។ រ៉ម យុន បាននិយាយទៀតថា គាត់បានត្រឹមតែលើកទឹកចិត្តប្រជាជនឲ្យធ្វើការច្រើនហើយ គាត់ក៏បានតវ៉ាជាមួយថ្នាក់លើរបស់គាត់ជាញឹកញាប់ដែរដើម្បីបញ្ចុះបញ្ចូលអង្គការថា «យើងបានធ្វើអស់ពីសមត្ថភាពទាំងញើសឈាមហើយ តែលទ្ធផលដែលយើងទទួលបានមិនសមនិងអ្វីដែលគ្រោងទុកទេ» ។ គាត់បានបន្តទៀតថា «យើងធ្វើតាមអង្គការប្រាប់យើងឲ្យធ្វើ តែយើងធ្វើមិនបាន» ព្រោះជារឿងមិនអាចធ្វើបានទេក្នុងការសម្រេចទិន្នផលឲ្យតាមផែនការនោះ ។ រ៉ម យុន បានផ្តល់សក្ខីកម្មថា អង្គការប្រាប់យើងថា យើងត្រូវតែធ្វើឲ្យបានល្អជាងមុនដើម្បី«អប់រំ»ប្រជាជន ដើម្បី«រក្សាជំហរបដិវត្តន៍» តែគាត់មិនដឹងថាត្រូវធ្វើយ៉ាងណាទេ ព្រោះប្រជាជននៅក្នុងភូមិ«បានធ្វើការអស់ពីចិត្តទៅហើយ» តែមូលដ្ឋានរបស់គាត់នៅតែមិនមាន«ប្រសិទ្ធភាព»នៅឡើយ ។

រ៉ម យុន ត្រូវបានណែនាំឲ្យ«ប្រយុទ្ធប្រឆាំង» និងវណ្ណៈជិះជាន់ តែគាត់មិនដឹងថាត្រូវប្រយុទ្ធប្រឆាំងដោយរបៀបណាទេ ហើយគាត់បានសារភាពដែរថា គាត់ធ្លាប់គិតសម្លាប់ខ្លួនដោយចងក ដើម្បីកុំឲ្យជួបនូវកិច្ចការលំបាកទាំងអស់នោះដែលបានដាក់បន្ទុកមកលើគាត់ ។ គាត់ត្រូវបានព្រមានថា គាត់នឹងត្រូវចាត់ទុកជា«ខ្មាំង» បើសិនជាគាត់មិនអាចដឹកនាំមូលដ្ឋានរបស់គាត់បានល្អដើម្បីបំពេញតាមផែនការដែលកំណត់ដោយអង្គការនោះ ។ តែគាត់នៅតែមិនដឹងថាតើត្រូវសម្រេចផែនការដោយរបៀបណាទេ «សូម្បីតែកូនជ្រូកក៏មិនមានចំណីស៊ីគ្រប់គ្រាន់ដែរនោះ ចុះទម្រាំតែមនុស្សយើងយ៉ាងម៉េចទៅ» ។

រ៉ម យុន បានបញ្ជាក់ទៀតថា ដោយសារការខ្វះចំណីអាហារនិងលក្ខខ័ណ្ឌរស់នៅមានការលំបាកបែបនេះទើបមានអ្នកខ្លះសម្លាប់ខ្លួន ព្រោះអ្នកទាំងនោះមិនអាចទ្រាំនិងស្ថានភាពលំបាកនោះបាន ។

កម្មាភិបាលនៅថ្នាក់តំបន់ និងភូមិភាគធ្វើពុតដោយបោកប្រាស់ខ្លួនឯងថា ប្រជាជនរស់នៅដោយសុខស្រួល មានម្ហូបអាហារហូបចុកគ្រប់គ្រាន់ តែតាមការពិត«យើងមិនបានផលិតស្រូវគ្រប់គ្រាន់ទេ ហើយក៏មិនបានដាំស្រូវគ្រប់គ្រាន់ដើម្បីឲ្យប្រជាជនហូបដែរ ម៉្យាងទៀត លេខាឃុំត្រូវបានស្តីបន្ទោសដោយសារតែគាត់មិនបានធ្វើតាមផែនការរបស់អង្គការ និងមិនអាចដឹកនាំប្រជាជនបានល្អ» ។

ជាចុងបញ្ចប់ រម៉ម យុន បាននិយាយដោយសង្ខេបថា «យើងមានជីវភាពក្រនិងគោកយ៉ាក» បន្ទាប់បញ្ចប់នូវការធ្វើសក្ខីកម្មរបស់ខ្លួន អង្គជំនុំជម្រះបានថ្លែងអំណរគុណដល់លោក និងបានប្រកាសសម្រាក ។

## សក្ខីកម្មរបស់ ក្លាន ហ្វីត

ក្រោយពីសម្រាកនៅពេលរសៀលរួចមក អង្គជំនុំជម្រះបានផ្តល់ឱកាសទៅភាគីព្រះរាជអាជ្ញាតាំងសំនួរសួរទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ្វីត ។ នៅក្នុងចម្លើយឆ្លើយតបទៅនឹងសំណួររបស់ព្រះរាជអាជ្ញា ក្លាន ហ្វីត បានឆ្លើយថា គាត់ត្រូវបាននាំទៅ«ចូលរួមអង្គមេទ្ទេញមួយ»តាមការបង្គាប់របស់ អៀង សារី ក្នុងឆ្នាំ១៩៧៥ ។ នៅក្នុងកិច្ចប្រជុំនោះ អៀង សារី បានសួរគាត់ថា តើគាត់ចង់«ធ្វើបដិវត្តន៍ឬអត់»កាលនោះ ក្លាន ហ្វីត មិនឆ្លើយអ្វីទាំងអស់ដោយសារតែគាត់ខ្លាចអង្គការ«នរណាក៏ខ្លាចអង្គការដែរ នៅពេលនេះ ខ្ញុំនៅតែខ្លាចអង្គការនៅឡើយ» ក្លាន ហ្វីត បញ្ជាក់ ។

ក្នុងឆ្នាំ១៩៧៦ ក្លាន ហ្វីត ត្រូវបានតែងតាំងជាលេខាស្រុក ។ ពេលនោះទ្រព្យសម្បត្តិឯកជនទាំងអស់ត្រូវប្រមូលជាសមូហភាព ហើយការហូបរួមចាប់ផ្តើមឡើង ។ លក្ខខ័ណ្ឌរស់នៅកាន់តែលំបាកទៅៗ ដូចគ្នាទៅនឹង រម៉ម យុន ដែរ ក្លាន ហ្វីត បានផ្តល់សក្ខីកម្មថា គាត់ធ្លាប់គិតចង់សម្លាប់ខ្លួនដោយចងក និងបានព្យាយាមសម្លាប់ខ្លួនដែរតែមិនបានសម្រេច ។

ក្រោយពីសង្កេតឃើញថា ក្លាន ហ្វីត មានការឈឺចាប់ផ្លូវចិត្តពេលដែលគាត់ឆ្លើយសំនួរ ព្រះរាជអាជ្ញាបានបង្វែរសំនួរមកសួរនាំអំពីព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥វិញ រហូតដល់ពេលដែលខ្មែរក្រហមកាន់កាប់អំណាច ។ ក្លាន ហ្វីត បានឆ្លើយថា គាត់ធ្លាប់ចូលរួមប្រជុំពីរដងក្រោមការដឹកនាំរបស់ អៀង សារី មុនឆ្នាំ១៩៧៥ ។

ក្លាន ហ្វីត បានធ្វើសក្ខីកម្មថា គាត់ធ្លាប់ឃើញ នួន ជា ដឹកនាំអង្គមេទ្ទេញចំនួនពីរដងក្រោយថ្ងៃជ័យជម្នះ ឆ្នាំ១៩៧៥ ក្នុងអង្គមេទ្ទេញនីមួយៗមានអ្នកចូលរួមពី៥០០ ទៅ៦០០នាក់នៅទីក្រុងភ្នំពេញ ។ ក្លាន ហ្វីត បានឲ្យដឹងថា ទោះបីជាកាលនោះគាត់មិនស្គាល់ថា នួន ជា ក៏ដោយ តែឈ្មោះ នួន ជា ត្រូវបានប្រកាសនាដើមដំបូងនៃអង្គមេទ្ទេញ ។ កម្មាភិបាលមកពីខេត្តផ្សេងៗ ចូលរួមក្នុងអង្គមេទ្ទេញ ហើយការធ្វើមេទ្ទេញម្តងៗ ត្រូវចំណាយពេលបីថ្ងៃ ក្នុងនោះក៏មានការណែនាំពីមាគ៌ាបក្ស

*កុម្មុយនីស្តកម្ពុជាដែរ ។ ក្វាន ហ៊ីត បានរំលឹកថា កាលពីដំបូងខ្លួនមិនដឹងថាតើអ្វីទៅជា បក្សកុម្មុយនីស្តកម្ពុជាទេ ហើយគាត់ហាក់ពីដូចជាធូរចិត្តបន្តិចនៅពេលដែលកាលនោះមានកម្មាភិបាលខ្លះមិនដឹងពីរឿងនេះដែរ ។ ក្វាន ហ៊ីត បាននិយាយទៀតថា វិន័យផ្សេងៗត្រូវបានយកមកពិភាក្សានៅក្នុងអង្គមេទ្ទេញ ហើយគាត់មិនអាចនឹកឃើញទេនូវអ្វីទាក់ទងនិងការពិភាក្សានេះ ទោះបីកាលនោះគាត់ទទួលបានឯកសារខ្លះក៏ដោយ ។ ក្វាន ហ៊ីត បានកត់ចំណាំថា ក្រោយពីបក្សកុម្មុយនីស្តកម្ពុជា ទទួលបានអំណាច ឃុំនីមួយៗ ត្រូវបានណែនាំឲ្យបង្កើតកងឈ្លបក្នុងមូលដ្ឋានប្រដាប់អាវុធចំនួនម្ភៃនាក់ដើម្បីការពារភូមិឃុំ ។*

*នៅពេលសួរអំពី ខៀវ សំផន ក្វាន ហ៊ីត បានបញ្ជាក់ថា គាត់មិនដែលបានជួប ខៀវ សំផន ទេ ហើយគាត់ក៏មិនដែលបានស្គាល់ ខៀវ សំផន ដោយផ្ទាល់ដែរ ។ ក្វាន ហ៊ីត ដឹងថា កិច្ចប្រជុំធ្វើឡើងនៅក្នុងព្រៃកាលពីអំឡុងមុនឆ្នាំ១៩៧៥ មានតែកម្មាភិបាលជាន់ខ្ពស់ប៉ុណ្ណោះទើបអាចចូលរួមប្រជុំបាន តែគាត់មិនដឹងថាតើនរណាខ្លះទេដែលបានចូលរួមប្រជុំនោះ ។*

*នៅពេលសួរអំពីផែនការជម្លៀសទីក្រុងភ្នំពេញ ក្វាន ហ៊ីត បាននិយាយថា “មានតែកម្មាភិបាលជាន់ខ្ពស់ប៉ុណ្ណោះ” ដូចជា អៀង សារី ដែលជាអ្នកចេញបញ្ជាក់កិច្ចការធំៗដូចជាផែនការជម្លៀសនេះបាន ។ ក្វាន ហ៊ីត បានសង្កេតឃើញថា អ្នកដែលត្រូវបានជម្លៀស“រស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺនយ៉ាងខ្លាំង” ។*

*ដោយដល់ពេលវេលាសមល្មមនឹងសម្រាក នៅវេលាម៉ោង ៤:០០ រសៀល អង្គជំនុំជម្រះប្រកាសបញ្ចប់សវនាការសម្រាប់ថ្ងៃអង្គារ ទី១០ មករា ឆ្នាំ២០១២ ហើយនឹងបន្តសវនាការ នៅថ្ងៃពុធ ទី១១ មករា ឆ្នាំ២០១២ សម្រាប់ការធ្វើសក្ខីកម្មទៅលើ នួន ជា នៅពេលព្រឹក និង ក្វាន ហ៊ីត នឹងធ្វើសក្ខីកម្មរបស់ខ្លួនបន្តទៀតនៅពេលរសៀល ។*

**- ចប់ -**